| ៨-ឧបាសិកា **ចក់ ស្រ៊ន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៣.៦០០ ដុល្លារ |
| ៩-ឧបាសិកា **ណៃ សេងលុយ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៣.៥០០ ដុល្លារ |
| ១០-ឧបាសក **រស់ លាង** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៣.៥០០ ដុល្លារ |
| ១១-ឧបាសក **ឈុំ ស៊ុយ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៣.៥០០ ដុល្លារ |
| ១២-ឧបាសក **ឃន ជាវ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៣.៥០០ ដុល្លារ |

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ ធ្វើពីបេតុងប្រក់ក្បឿង ២ជាន់ មានទំហំ ១១ម៉ែត្រ x ២២ម៉ែត្រ និងចាក់សាបក្នុងទីធ្លាវត្ត នៅ**វត្តឧត្តមមានជ័យ** ស្ថិតនៅក្នុងឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០១ គ្រឿង ប្រគេន**

ព្រះតេជគុណ **ណេន យ៉ុនយុទ្ធាន** ព្រះចៅអធិការវត្តឧត្តមមានជ័យ បច្ច័យចំនួន ២៥.០០០ ដុល្លារ

**ខ. មេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សឫទ្ធិចំនួន ០៣ គ្រឿង ផ្តល់ជូន :**

១-ឧបាសក **ជ័យ យិន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២០.០០០ ដុល្លារ

២-ឧបាសិកា **គាំង នីន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២០.០០០ ដុល្លារ

៣-ឧបាសិកា **សៀក លាងជាង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២០.០០០ ដុល្លារ

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..១២៩..អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

មាត្រា ១.–

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ផ្ដល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន ១៨រូប ដែលបានលះបង់កម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យអោយមានការរីកចម្រើនគួរជាទិមោទនៈ ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមាសការងារចំនួន ០៤ គ្រឿង ផ្ដល់ជូន :**

១-លោកអនុសេនីយ៍ឯក **កែម ណារ៉ែន** មន្ត្រីការិយាល័យជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង អត្តលេខ ៦៤២៤២

២-លោក **យឿន យៀប** សប្បុរសជននៅខេត្តព្រៃវែង

៣-លោក **ផាន់ អ៊ីម** សប្បុរសជននៅខេត្តព្រៃវែង

៤-លោក **គោគ ជាវ៉ូ** សប្បុរសជននៅខេត្តព្រៃវែង

**ខ. មេដាយប្រាក់ការងារចំនួន ០៧ គ្រឿង ផ្ដល់ជូន :**

១-លោកអនុសេនីយ៍ទោ **ហេង ឧត្ដម** នាយផ្នែកការិយាល័យបណ្ដុះបណ្ដាល នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង អត្តលេខ ៥៨៥៧១

២-លោកអនុសេនីយ៍ទោ **រ៉ាត់ បូរិន្ទ** មេប៉ុស្ដិ៍នគរបាលឃុំព្រែកណ្ដៀង ខេត្តព្រៃវែង អត្តលេខ ៦៩៥៥៨

៣-លោកអនុសេនីយ៍ទោ **កុសល វិភៈវៈ** នាយផ្នែកការិយាល័យជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង អត្តលេខ ៥៨៥៤៩

៤-លោក **ហេង សុផាន់ណា** មន្ត្រីក្រសួងមហាផ្ទៃ

៥-កញ្ញា **ហេង សុចត្ថា** មន្ត្រីក្រសួងមហាផ្ទៃ

៦-កញ្ញា **សួន ផល្លីន** មន្ត្រីក្រសួងមហាផ្ទៃ

៧-ឧបាសក **នៅ ជឿន** អាចារ្យវត្តសុវណ្ណរង្សី ខេត្តព្រៃវែង

**គ. មេដាយសិរីវឌ្ឍនភាពរចនាចំនួន ០៧ គ្រឿង ផ្តល់ជូន :**

១-លោកអនុសេនីយ៍ទោ **រឹម ចន្ថា** មន្ត្រីនគរបាលខេត្តព្រៃវែង

២-លោកអនុសេនីយ៍ត្រី **ឡេង សុខឿន** មន្ត្រីការិយាល័យបណ្តុះបណ្តាល នៃស្នងការដ្ឋាននគរបាល ខេត្តព្រៃវែង អត្តលេខ ៧៥៩៨៤

៣-លោក **ស៊ិន សុខហេង** មន្ត្រីសាលាស្រុកកំចាយមារ

៤-លោកស្រី **គន្ធា សេរីវឌ្ឍនា** មន្ត្រីសាលាស្រុកកំចាយមារ

៥-លោកស្រី **អេង សុផាន់ណា** មន្ត្រីសាលាស្រុកកំចាយមារ

៦-លោកស្រី **យ៉េន រចនា** មន្ត្រីសាលាស្រុកកំចាយមារ

៧-លោក **សៅ ប៊ុនថន** មន្ត្រីសាលាស្រុកកំចាយមារ

មាត្រា ២._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា
លេខ ធ៧-០១៥-១៩៣ ប្រ.ក

ប្រកាស
ស្តីពី
ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៣៧ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥

សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងបង្កើតយន្តការដោះស្រាយតម្រូវការសន្ទនីយភាពចាំបាច់ ដើម្បីឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅបន្តដំណើរការជាប្រក្រតី ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅទប់ស្កាត់ហានិភ័យជាប្រព័ន្ធកើតឡើងដោយសារការផ្លាស់ប្តូរស្ថានភាព ឬនិន្នាការទីផ្សារដែលមិនអាចព្យាករណ៍ទុកមុនបាន ដែលនាំឲ្យមានកង្វះសន្ទនីយភាពជាយថាហេតុ ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើពីសាធារណជន និងស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន" ។

គ្រឹះស្ថានត្រូវមានស្ថានភាពដូចខាងក្រោម ៖

- មានសាធនភាព មានចំណេញ និងអនុវត្តបានពេញលេញតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន
- មានវត្ថុធានាដែលអាចទទួលយកបានដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៤.-**

គណៈគ្រប់គ្រងគ្រឹះស្ថានត្រូវបង្កើតគោលនយោបាយប្រុងប្រយ័ត្ន ដោយកំណត់ឱ្យបានច្បាស់លាស់ពីកម្រិតហានិភ័យសន្ទនីយភាពដែលអាចទទួលយកបាន រៀបចំផែនការបំពេញសន្ទនីយភាព (Contingency Liquidity Plan) ស្របតាមកម្រិតហានិភ័យនោះ និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយនិងផែនការជាប្រចាំដែលឆ្លុះបញ្ចាំងពីស្ថានភាពផ្លាស់ប្ដូររបស់ទីផ្សារ ។

ការស្នើសុំសន្ទនីយភាពពីធនាគារជាតិនៃកម្ពុជាត្រូវចាត់ទុកថាជាជម្រើសចុងក្រោយរបស់គ្រឹះស្ថានបន្ទាប់ពីបានប្រើប្រាស់អស់លទ្ធភាពនូវជម្រើសផ្សេងៗទៀត ។

**ប្រការ ៥.-**

សន្ទនីយភាពត្រូវបានផ្ដល់ក្នុងកាលៈទេសៈពិសេស ដែលគ្រឹះស្ថានមិនត្រូវចាត់ទុកសន្ទនីយភាពនេះជាការផ្ដល់ឥណទានជាលក្ខណៈប្រព័ន្ធឡើយ ហើយមិនត្រូវពឹងផ្អែកទាំងស្រុងទៅលើឥណទានទាំងនេះ ដើម្បីជាមធ្យោបាយគ្រប់គ្រងកង្វះសន្ទនីយភាពឡើយ ។ ការផ្ដល់សន្ទនីយភាព ត្រូវបានកំណត់ដូចខាងក្រោម ៖

(១) សន្ទនីយភាពត្រូវបានផ្ដល់ដោយផ្អែកលើវត្ថុធានា

(២) ឥណប្រតិទានរបស់វត្ថុធានាត្រូវតែមានរយៈពេលវែងជាងឥណប្រតិទានរបស់សន្ទនីយភាព

(៣) ធនាគារជាតិនៃកម្ពុជាផ្ដល់សន្ទនីយភាពដែលមានឥណប្រតិទានយ៉ាងយូរ៣០ថ្ងៃ ។ ក្នុងករណីចាំបាច់ គ្រឹះស្ថានអាចស្នើសុំពន្យារពេលបាន ។ ធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យពន្យារពេលត្រឹម២លើកប៉ុណ្ណោះ ដែលក្នុង១លើកអាចមានរយៈពេលយ៉ាងយូរ៣០ថ្ងៃ

(៤) ធនាគារជាតិនៃកម្ពុជាអាចផ្ដល់សន្ទនីយភាពត្រឹមហុកសិបភាគរយ (៦០%) នៃតម្លៃវត្ថុធានា និងអាចបង្កើនឬបន្ថយទៅតាមទំហំហានិភ័យជាក់ស្ដែងនៃវត្ថុធានា

(៥) សន្ទនីយភាពមានទំហំខ្ពស់បំផុតត្រឹមហាសិបភាគរយ (៥០%) នៃប្រាក់បម្រុងកាតព្វកិច្ចរបស់គ្រឹះស្ថាន

(៦) អត្រាការប្រាក់ត្រូវតែខ្ពស់ជាងអត្រាការប្រាក់នៃសន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ (Standing Liquidity Facilities) ។ ការប្រាក់ត្រូវគិតលើមូលដ្ឋានបង្គរប្រចាំថ្ងៃនៃសមតុល្យដក់សល់ ចាប់ពីថ្ងៃទទួលបានសន្ទនីយភាពរហូតដល់ឥណប្រតិទាន ។ គ្រឹះស្ថានអាចទូទាត់សងផ្នែកខ្លះ ឬទាំងស្រុងនៃសន្ទនីយភាពមុនឥណប្រតិទាន ។ ក្នុងករណីគ្រឹះស្ថានមិនបានទូទាត់សងសន្ទនីយភាពតាមកាលកំណត់ ធនាគារជាតិនៃកម្ពុជានឹងអនុវត្តអត្រាការប្រាក់ពិន័យទៅលើប្រាក់ដើមបូកនឹងមូលធនកម្មការប្រាក់ (Capitalized Interest) រហូតដល់មានការទូទាត់សងទាំងស្រុង និង/ឬចាត់វិធានការដទៃទៀតតាមច្បាប់ជាធរមាន ។

**ប្រការ ៦**.-

គ្រឹះស្ថានដែលមានតម្រូវការសន្ទនីយភាពត្រូវដាក់ពាក្យស្នើសុំជាមុន ដោយភ្ជាប់មកជាមួយនូវ ៖

(១) កិច្ចសន្យាស្នើសុំសន្ទនីយភាព និងកិច្ចសន្យាដាក់វត្ថុធានា

(២) ការវាយតម្លៃស្ថានភាពរួមរបស់គ្រឹះស្ថានដើម្បីបង្ហាញថាគ្រឹះស្ថានកំពុងមានសាធនភាព និងមានចំណេញ

(៣) ការព្យាករណ៍សន្ទនីយភាពដោយមានសម្មតិកម្មច្បាស់លាស់ និងប៉ាន់ស្មានកាលបរិច្ឆេទកង្វះសន្ទនីយភាពរួមទាំងការសាកល្បងសេណារីយ៉ូ (Stress Test Scenario) ផងដែរ

(៤) ការវិភាគអំពីការផ្លាស់ប្តូរនិន្នាការ និង/ឬស្ថានភាពទីផ្សារដែលអាចប៉ាន់ស្មានបាននូវកង្វះសន្ទនីយភាព

(៥) ផែនការសកម្មភាពដែលអាចទុកចិត្តបានក្នុងការដោះស្រាយកង្វះសន្ទនីយភាពដោយមានការប៉ាន់ស្មាន និងដោយប្រុងប្រយ័ត្ននូវពេលវេលាចាំបាច់សម្រាប់អនុវត្តផែនការសកម្មភាពនោះ និងទូទាត់សងមកវិញនូវសន្ទនីយភាព

(៦) ការព្យាករណ៍អំពីផលប៉ះពាល់និងបច្ច័យដែលអាចកើតមានឡើងក្នុងការអនុវត្តផែនការសកម្មភាពលើលទ្ធភាពចំណេញ (តម្លៃនៃមូលនិធិ ប្រភពផ្សេងទៀតនៃមូលនិធិ ការជម្រះទ្រព្យសកម្ម) និងសាធនភាព ។

ធនាគារជាតិនៃកម្ពុជាអាចស្នើសុំព័ត៌មាន ឬទិន្នន័យបន្ថែមទៀតពីគ្រឹះស្ថាន ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ សវនករផ្ទៃក្នុង សវនករឯករាជ្យ បុគ្គល ឬអង្គភាពផ្សេងទៀតតាមការចាំបាច់ ។

**ប្រការ ៧** .-

គ្រឹះស្ថាន ត្រូវបង់សោហ៊ុយទម្រង់ការ សូន្យក្បៀសប្រាំភាគរយ (0,៥%) នៃទំហំសន្ទនីយភាពដែលបានអនុម័ត ។

**ប្រការ ៨**.-

បន្ទាប់ពីទទួលបានសន្ទនីយភាព គ្រឹះស្ថានត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជាដូចតទៅ៖

(១) រាល់ព្រឹត្តិការណ៍ដែលកើតមាន និងការផ្លាស់ប្តូរចំណាត់ថ្នាក់ចំពោះវត្ថុធានាដោយមិនកំណត់ត្រឹមតែការមិនសងប្រាក់ឬការទូទាត់សងមុនកាលកំណត់ ។ ក្នុងករណីមានការផ្លាស់ប្តូរ គ្រឹះស្ថានត្រូវដាក់សំណើពាក់ព័ន្ធនឹងការដាក់វត្ថុធានាថ្មីជំនួសវត្ថុធានាចាស់

(២) ការវិវត្តនៃការអនុវត្តផែនការសកម្មភាព និងផលប៉ះពាល់លើស្ថានភាពសន្ទនីយភាពរបស់គ្រឹះស្ថាន

(៣) ការលំបាកនិងបញ្ហាប្រឈមផ្សេងៗទៀត ដែលអាចកើតមានក្នុងការអនុវត្តផែនការសកម្មភាព ។

ក្នុងករណីមានកង្វះសន្ទនីយភាពកាន់តែធ្ងន់ធ្ងរ គ្រឹះស្ថានត្រូវផ្តល់របាយការណ៍ប្រចាំថ្ងៃស្តីពីលំហូរសាច់ប្រាក់ចេញ-ចូល របាយការណ៍ស្តីពីការព្យាករណ៍គម្លាតសន្ទនីយភាពនៅថ្ងៃបន្ទាប់ និង/ឬអាចត្រូវបានត្រួតពិនិត្យដល់ទីកន្លែង ។

**ប្រការ ៩.-**

ប្រកាសលេខធ៧-០៩-០១៣ ប្រក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ស្តីពីការផ្តល់ឥណទានវិបារូបន៍ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលខ្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១០.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១១.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៥

**ទេសាភិបាល**

ជា ចាន់តូ

**<u>កន្លែងទទួល ៖</u>**

- ដូចប្រការ ១០"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**<u>ចម្លងជូន ៖</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៥-១៥៤ ប្រក

## ប្រកាស
## ស្តីពី
## ការចែករំលែកព័ត៌មានត្រួតពិនិត្យរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករក្នុងនិងក្រៅប្រទេស

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៣៧ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការ ប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ពន្ធ័របស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការចែករំលែកព័ត៌មានត្រួតពិនិត្យរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅ ៖

- ពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យក្រុមនិងសម្ព័ន្ធគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង
- បង្កើតយន្តការការពារនិងដោះស្រាយវិបត្តិ ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តក្របខ័ណ្ឌចែករំលែកព័ត៌មានត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស ។

**ប្រការ ៤.-**

ក្របខ័ណ្ឌចែករំលែកព័ត៌មានអាចត្រូវបានរៀបចំឡើងតាមទម្រង់ដូចខាងក្រោម ៖

(១) កិច្ចប្រជុំទ្វេភាគីរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស

(២) អនុស្សារណៈយល់គ្នារវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស

(៣) កិច្ចប្រជុំរវាងមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស និង

(៤) កិច្ចទំនាក់ទំនងផ្សេងទៀត តាមការចាំបាច់ ។

**ប្រការ ៥.-**

ការចែករំលែកព័ត៌មានត្រួតពិនិត្យត្រូវស្របតាមលក្ខខណ្ឌនៃកិច្ចសហប្រតិបត្តិការ គោរពតាមគោលការណ៍នៃការរក្សាការសម្ងាត់វិជ្ជាជីវៈ និងច្បាប់ជាធរមាន ។

អាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករក្នុងនិងក្រៅប្រទេស ដែលទទួលបានព័ត៌មានត្រូវរក្សាការសម្ងាត់ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាជ្ញាធរដែលបានផ្តល់ព័ត៌មាន ។

**ប្រការ ៦.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពនូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥

**ទេសាភិបាល**

ជា.ចាន់តូ

**កន្លែងទទួល ៖**

- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន ៖**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៥-៣៨៩ ប្រ.ក

**ប្រកាស**
**ស្តីពី**
**អនុបាតក្របខ័ណ្ឌសន្ទនីយភាព**

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួល ប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥

**សម្រេច**

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខណៈវិនិច្ឆ័យក្នុងការគណនា និងកំណត់កម្រិតអប្បបរមានៃអនុបាតក្របខ័ណ្ឌសន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើពីសាធារណជន ដែលតទៅនេះហៅថា "គ្រឹះស្ថាន" ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅ ៖

- បង្កើនភាពធន់រយៈពេលខ្លី (Short-Term Resilience) ចំពោះហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថាន
- ធានាថាគ្រឹះស្ថានមានបរិមាណទ្រព្យសកម្មសន្ទនីយគ្រប់គ្រាន់មិនជាប់កាតព្វកិច្ច ដែលអាចបំលែងជាសាច់ប្រាក់ដោយមិនខាតបង់ ឬខាតបង់តិចតួចពីតម្លៃនៅលើទីផ្សារ ដើម្បីបំពេញតម្រូវការសន្ទនីយភាពក្នុងស្រ្តេសសេណារីយ៉ូ (Stress Scenario) សម្រាប់រយៈពេល៣០ថ្ងៃ និង
- ធានាថា នៅពេលដែលអនុបាតគ្របខ័ណ្ឌសន្ទនីយភាពនេះធ្លាក់ចុះក្រោមកម្រិតកំណត់អប្បបរមា គណៈគ្រប់គ្រងគ្រឹះស្ថានត្រូវចាត់វិធានការកែតម្រូវបន្ទាន់ ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៤.-**

គ្រឹះស្ថានត្រូវរក្សាអនុបាតគ្របខ័ណ្ឌសន្ទនីយភាពយ៉ាងតិច ១០០% (មួយរយភាគរយ) គ្រប់ពេលវេលាចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ។

អនុបាតគ្របខ័ណ្ឌសន្ទនីយភាព មានសមាសធាតុពីរគឺ ៖

- ភាគយក ៖ តម្លៃទីផ្សារនៃបរិមាណទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបាន ដូចមានកំណត់ក្នុងប្រការ៧
- ភាគបែង ៖ លំហូរចេញសុទ្ធនៃសាច់ប្រាក់ដែលរំពឹងទុកគណនាស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសនេះ។

$$\text{អនុបាតគ្របខ័ណ្ឌសន្ទនីយភាព} = \frac{\text{បរិមាណទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបាន}}{\text{លំហូរចេញសុទ្ធនៃសាច់ប្រាក់ដែលរំពឹងទុករយៈពេល៣០ថ្ងៃ}} \geq \text{១០០\%}$$

គ្រឹះស្ថានដែលបង្កើតឡើងនៅកម្ពុជា ត្រូវគណនាទាំងកម្រិតគ្រឹះស្ថាននិងកម្រិតគួបសរុប ចំណែកគ្រឹះស្ថានដែលជាសាខារបស់ធនាគារបរទេស ត្រូវគណនាត្រឹមកម្រិតគ្រឹះស្ថាន ។

**ប្រការ ៥.-**

គ្រឹះស្ថានត្រូវអនុវត្តការគណនាអនុបាតគ្របខ័ណ្ឌសន្ទនីយភាព ស្របតាមគំរូរបាយការណ៍ថ្មីចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៦ ជាដំណាក់កាលរហូតបំពេញបានទាំងស្រុងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ។

គ្រឹះស្ថានត្រូវរក្សាជាប្រចាំនូវបរិមាណទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបានគ្រប់គ្រាន់ ដើម្បីឲ្យកម្រិតអនុបាតដែលបានកំណត់ស្របទៅតាមពេលវេលា ដូចខាងក្រោម ៖

| ចាប់អនុវត្ត | ០១ កញ្ញា ២០១៦ | ០១ កញ្ញា ២០១៧ | ០១ កញ្ញា ២០១៨ | ០១ មិថុនា ២០១៩ | ០១ មករា ២០២០ |
|---|---|---|---|---|---|
| អនុបាតអប្បបរមា | ៦០% | ៧០% | ៨០% | ៩០% | ១០០% |

**ប្រការ ៦**.-

គ្រឹះស្ថានត្រូវមានទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបានបន្ថែមទៀត លើសពីកម្រិតកំណត់នៃអនុបាតនេះស្របតាមគោលនយោបាយនិងការទទួលយកបាននៃកម្រិតហានិភ័យសន្ទនីយភាពរបស់ខ្លួន ។

គ្រឹះស្ថានត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់ធនាគារជាតិនៃកម្ពុជា នៅពេលមិនគោរពបានតាមកម្រិតកំណត់នៃអនុបាតនេះ ឬនៅពេលព្យាករណ៍ដឹងថាមិនអាចបំពេញតាមកម្រិតកំណត់ ។

គ្រឹះស្ថានត្រូវគណនាអនុបាតនេះដោយឡែកពីគ្នាសម្រាប់ទ្រព្យសកម្មនិងទ្រព្យអកម្ម ដែលចារឹកជាប្រាក់រៀល ដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងៗទៀតរួមគ្នា ព្រមទាំងសរុបរូបិយប័ណ្ណទាំងអស់បញ្ចូលគ្នា ។ ប្រកាសនេះអនុវត្តចំពោះអនុបាតក្របខ័ណ្ឌសន្ទនីយភាព ដែលត្រូវបានគណនាជាសរុបរូបិយប័ណ្ណទាំងអស់បញ្ចូលគ្នាគិតជា ប្រាក់រៀល ។

**ប្រការ ៧**.-

ទ្រព្យសកម្មសន្ទនីយអាចទទួលយកបាន គឺជាទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ (High Quality Liquid Assets) និងទ្រព្យសកម្មសន្ទនីយផ្សេងទៀត ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។ ទ្រព្យសកម្មដែលត្រូវបញ្ចូលនៅក្នុងប្រភេទនីមួយៗ គឺជាទ្រព្យសកម្មដែលគ្រឹះស្ថានកាន់កាប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីថ្ងៃរាយការណ៍នីមួយៗ ដោយមិនគិតពីឥណប្រតិទាន ។

ទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ ត្រូវគិតតម្លៃពេញតាមទីផ្សារ ១០០% (មួយរយភាគរយ) ចំណែក ទ្រព្យសកម្មសន្ទនីយផ្សេងទៀត ត្រូវកាត់បន្ថយតម្លៃទាបជាងទីផ្សារ (Haircut) ១៥% (ដប់ប្រាំភាគរយ) ទៅ ២៥% (ម្ភៃប្រាំភាគរយ) ។

ទំហំទ្រព្យសកម្មសន្ទនីយផ្សេងទៀត ត្រូវកម្រិតអតិបរមា ៤០% (សែសិបភាគរយ) នៃទំហំទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបាន ។

សំពៀតនៃទ្រព្យសកម្មសន្ទនីយផ្សេងទៀតត្រូវតែធ្វើពិពិធកម្មតាមប្រភេទនៃទ្រព្យសកម្ម និងអ្នកបោះផ្សាយ ។

**ប្រការ ៨**.-

លំហូរចេញសុទ្ធនៃសាច់ប្រាក់ដែលរំពឹងទុក = លំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុក – លំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុក (ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីថ្ងៃរាយការណ៍នីមួយៗ) ។

លំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុក = សមតុល្យដក់សល់នៃខ្ទង់ទ្រព្យអកម្មនិងខ្ទង់ក្រៅតារាងតុល្យការ x អត្រារំពឹងទុកនៃលំហូរចេញ ។

លំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុក = សមតុល្យដក់សល់នៃខ្ទង់ត្រូវទទួលតាមការសន្យា x អត្រារំពឹងទុកនៃលំហូរចូល ។

ពេលគណនាលំហូរចូលនៃសាច់ប្រាក់ គ្រឹះស្ថានត្រូវគិតតែលំហូរចូលទ្រព្យសកម្មស្តង់ដារដក់សល់ និងមិនរំពឹងថាខកខានទូទាត់សងក្នុងរយៈពេល៣០ថ្ងៃ ។

លំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុកត្រូវបានកំណត់ត្រឹម ៧៥% (ចិតសិបប្រាំភាគរយ) នៃលំហូរចេញសាច់ប្រាក់ដែលរំពឹងទុក ដែលមានន័យថា លំហូរចេញសុទ្ធនៃសាច់ប្រាក់អប្បបរមាគឺ ២៥% (ម្ភៃប្រាំភាគរយ) នៃលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុកសរុប ។

នៅក្នុងការគណនាអនុបាតគ្របខណ្ឌសន្ទនីយភាព គ្រឹះស្ថានមិនត្រូវយកទ្រព្យសកម្មណាមួយមកគណនាពីរដងទេ (Double Count Items) ។ ប្រសិនបើទ្រព្យសកម្មណាមួយត្រូវបានគិតបញ្ចូលទៅក្នុងបរិមាណនៃទ្រព្យសកម្មសន្ទនីយដែលអាចទទួលយកបានរួចហើយ ដូចមានក្នុងប្រការ៧ នៃប្រកាសនេះ ទ្រព្យសកម្មនេះ មិនត្រូវបានបញ្ចូលសម្រាប់គណនាលំហូរចេញសុទ្ធនៃសាច់ប្រាក់ទៀតឡើយ ។

**ប្រការ ៩**.-

លំហូរចេញនៃសាច់ប្រាក់ ដែលពាក់ព័ន្ធប្រាក់បញ្ញើមានកាលកំណត់ មិនត្រូវរាប់បញ្ចូលក្នុងការគណនាលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុកទេ ក្នុងករណី ៖

- មានឥណប្រតិទានលើសពី ៣០ថ្ងៃ ឬ
- មានការជូនដំណឹងអំពីការដកប្រាក់ លើសពី ៣០ថ្ងៃ

ប៉ុន្តែ ប្រសិនបើគ្រឹះស្ថានអនុញ្ញាតឲ្យម្ចាស់ប្រាក់បញ្ញើដកប្រាក់នោះមុនឥណប្រតិទានទោះបីមានពិន័យការប្រាក់ក៏ដោយ ប្រាក់បញ្ញើទាំងនេះ ត្រូវចាត់ទុកដូចជាប្រភេទប្រាក់បញ្ញើដកបានតាមតម្រូវការ និងត្រូវបញ្ចូលក្នុងការគណនាលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុក ។

លំហូរចូលនៃសាច់ប្រាក់ពីការបោះផ្សាយប័ណ្ណបំណុលថ្មីណាមួយក្នុងរយៈពេល ៣០ថ្ងៃខាងមុខ មិនត្រូវគិតបញ្ចូលក្នុងការគណនាលំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុកទេ ។

លំហូរដែលកើតចេញពីប៉ូស៊ីសិននៃប្រតិបត្តិការឧបករណ៍និស្សន្ទ អាចត្រូវបានកាត់កងដោយសមភាគី ប្រសិនបើមានកិច្ចសន្យារវាងភាគីទាំងពីរ ។ ចំពោះប៉ូស៊ីសិន និងលំហូរផ្សេងទៀតដែលចែងក្នុងប្រកាសនេះ គ្រឹះស្ថានត្រូវផ្តល់ការវិភាគនិងភស្តុតាងច្បាស់លាស់ ដើម្បីបញ្ជាក់ពីលំហូរចេញ និងលំហូរចូលនៃឧបករណ៍និស្សន្ទ ដែលគ្រឹះស្ថានបានយកមកគិត ។

**ប្រការ ១០**.-

ចំពោះគ្រឹះស្ថានជាបុគ្គលសម្ព័ន្ធ ឬជាសាខារបស់ធនាគារបរទេស ធនាគារជាតិនៃកម្ពុជាអាចអនុញ្ញាតឲ្យគ្រឹះស្ថានទាំងនោះទទួលទុនពីទីស្នាក់ការកណ្តាលតាមរយៈកិច្ចសន្យាផ្តល់ទុន ។ ក្នុងករណីនេះ កិច្ចសន្យាផ្តល់ទុនទាំងនោះ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- ដែលមិនអាចបដិសេធបានពីទីស្នាក់ការកណ្តាល
- ដែលអនុញ្ញាតឲ្យទទួលទុនសរុបក្នុងរយៈពេលតិចជាង៣០ថ្ងៃ
- ដែលត្រូវរៀបចំជាលាយលក្ខណ៍អក្សរឲ្យបានត្រឹមត្រូវ
- ដែលមានបញ្ជាក់ពីទំហំទឹកប្រាក់ច្បាស់លាស់ និង
- ត្រូវមានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើម ។

ទំហំទឹកប្រាក់ក្នុងកិច្ចសន្យានេះដែលអាចឲ្យលំហូរចូលនៃសាច់ប្រាក់កើនឡើង ត្រូវបានកំណត់ត្រឹមតែ ៤០% (សែសិបភាគរយ) នៃលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុកសរុប ។

**ប្រការ ១១**.-

គ្រឹះស្ថានត្រូវមានរចនាសម្ព័ន្ធផ្ទៃក្នុង និងការត្រួតពិនិត្យផ្ទៃក្នុងសមស្របដែលអាចធានាអនុវត្តបានតាមប្រកាសនេះ ។

**ប្រការ ១២**.-

អនុបាតគ្របខណ្ឌសន្ទនីយភាព ត្រូវបានប្រើប្រាស់ជាប្រចាំក្នុងការតាមដាន និងត្រួតពិនិត្យហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថាន ។ គ្រឹះស្ថានត្រូវគោរពឲ្យបានតាមកម្រិតកំណត់នៃអនុបាតនេះជាបន្តបន្ទាប់ ។

គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍ស្តីពីអនុបាតនេះ មកធនាគារជាតិនៃកម្ពុជាជារៀងរាល់ខែ ។ ករណីមានស្ថានភាពតានតឹង (Stress Situation) ធនាគារជាតិនៃកម្ពុជាមានសិទ្ធិតម្រូវឲ្យគ្រឹះស្ថានរាយការណ៍ប្រចាំសប្តាហ៍ ឬប្រចាំថ្ងៃ បន្ថែមទៀត ។

**ប្រការ ១៣**.-

ត្រូវបានចាត់ទុកជានិរាករណ៍ ៖

- ប្រកាសលេខ ធ៧-០០-៣៨ ប្រ.ក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី សាច់ប្រាក់ងាយស្រួលរបស់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ
- ប្រកាសលេខ ធ៧-០២-១៨៧ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ធ៧-០៤-២០៧ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី វិសោធនកម្មលើប្រកាសស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង

- ប្រកាសលេខ ធ៧-០៧-១៦៣ ប្រ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការផ្តល់អាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំណុចទី៤ នៃប្រការ ៣ ។

**ប្រការ ១៤.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ។

**ប្រការ ១៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥

**ទេសាភិបាល**

**ជា ចាន់តូ**

**កន្លែងទទួល ៖**

- ដូចប្រការ ១៤"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន ៖**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

## របាយការណ៍ប្រចាំខែ ស្តីពី អនុបាតគ្របដណ្តប់សន្ទនីយភាព
Monthly Report on Liquidity Coverage Ratio

| | |
|---|---|
| ឈ្មោះគ្រឹះស្ថាន ៖ Name of the Institution : | |
| កាលបរិច្ឆេទ ៖ Reporting Date : | |

| អត្រាប្តូរប្រាក់ ១ ដុល្លារអាមេរិក (Exchange rate 1 USD) = | KHR |
|---|---|

| គិតជាលានរៀល (In million riels) | | | | ចំនួនទឹកប្រាក់មិនទាន់ថ្លឹង Non weighted amounts | | | ចំនួនទឹកប្រាក់ក្រោយថ្លឹង Weighted amounts | | | សរុប Total |
|---|---|---|---|---|---|---|---|---|---|---|
| ទ្រព្យសកម្ម ASSETS | | | | KHR | USD | Other currencies | KHR | USD | Other currencies | |
| ទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ HQLA | 1.11 | 1 | សាច់ប្រាក់ និងកាសក្នុងដៃ<br>Notes and coins | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 1.12 | 1 | អតិរេកប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជា<br>Reserves requirement with the NBC > minimum reserve requirement | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 1.13 | 1 | ប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា<br>Reserves requirement with the NBC in KHR | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 1.14 | 0.7 | ប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា<br>Reserves requirement with the NBC in USD | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 1.15 | 1 | សមតុល្យប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា លើកលែងគណនីទូទាត់ និងគណនីប្រាក់ធានាលើដើមទុន<br>Amounts deposited at the NBC excluding settlement account and capital guarantee account | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 1.16 | 1 | មូលបត្រអាចជួញដូរបាន (និង ប្រភេទមូលបត្រផ្សេងទៀត) បោះផ្សាយដោយធនាគារជាតិនៃកម្ពុជា<br>NCDs (and any other securities) issued by the NBC | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 1.17 | 1 | តម្លៃទីផ្សារនៃមូលបត្រប័ណ្ណបំណុលអាចជួញដូរបានមិនជាប់កាតព្វកិច្ចរបស់ ឬធានាដោយ ស្ថាប័នអធិបតេយ្យ និងធនាគារកណ្តាល ដែលមានចំណាត់ថ្នាក់ AAA ទៅ AA- និង ធនាគារសម្រាប់ការទូទាត់អន្តរជាតិ មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារកណ្តាលនៃសហគមន៍អឺរ៉ុប សហភាពអឺរ៉ុប និងធនាគារអភិវឌ្ឍន៍ ដែលមានចំណាត់ថ្នាក់ AAA<br>Market value of unencumbered marketable debt securities on or guaranteed by sovereigns and central banks, with rating comprised between AAA and AA- included BIS, IMF, ECB, EU, and MDBs when rated AAA | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | សរុប ១ = ផលបូក (១.១១ ដល់ ១.១៧)<br>Total 1 = Σ (1.11 ; 1.17) | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| ទ្រព្យសកម្មសន្ទនីយផ្សេងទៀត OLA | 1.21 | 0.85 | តម្លៃទីផ្សារនៃមូលបត្រប័ណ្ណបំណុលអាចជួញដូរបានមិនជាប់កាតព្វកិច្ចរបស់ ឬធានាដោយ ស្ថាប័នអធិបតេយ្យ និងធនាគារកណ្តាល ដែលមានចំណាត់ថ្នាក់ A+ ទៅ A-<br>Market value of unencumbered marketable debt securities on or guaranteed by sovereigns and central banks, with rating between A+ and A- | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 1.22 | 0.85 | តម្លៃទីផ្សារនៃមូលបត្រប័ណ្ណបំណុលអាចជួញដូរបានមិនជាប់កាតព្វកិច្ចរបស់ ឬធានាដោយ សហគ្រាស/អង្គភាពសាធារណៈ ធនាគារអភិវឌ្ឍន៍ ដែលពុំបានបូកបញ្ចូលនៅក្នុង ១.១៧ ដែលមានចំណាត់ថ្នាក់ខ្ពស់ជាង ឬ ស្មើ A-<br>Market value of unencumbered marketable debt securities on or guaranteed by Public Sector Entities (PSEs) and MDBs not included in 1.17 with rating higher or equal to A- | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 1.23 | 0.85 | មូលបត្រប័ណ្ណបំណុលអាចជួញដូរបានមិនជាប់កាតព្វកិច្ចដែលអាចទទួលយកបាន (រួមទាំងផលបត្រពាណិជ្ជកម្ម) និង Covered Bonds ដែលមានចំណាត់ថ្នាក់ខ្ពស់ជាង ឬ ស្មើ AA-<br>Unencumbered eligible debt securities (including commercial paper) and covered bonds, with rating higher or equal to AA- | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 1.24 | 0.75 | មាស<br>Gold for own account | | | | 0.00 | 0.00 | 0.00 | 0.00 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប ២ = អប្បបរមា នៃ [OLA ; 40% (HQLA+OLA)]<br>Total 2 = Minimum [OLA ; 40% (HQLA+OLA)] | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| ទ្រព្យសកម្មសរុប<br>Total ASSETS | | | សរុប ៣ = សរុប ១ + សរុប ២<br>Total 3 = Total 1 + Total 2 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| លំហូរចេញសុទ្ធនៃសាច់ប្រាក់ដែលរំពឹងទុក = លំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុក - លំហូរចូលនៃសាច់ប្រាក់ដែលរំពឹងទុក<br>NET CASH OUTFLOWS = expected cash outflows - expected cash inflows | | | | | | | | | | |
| | លំហូរចេញ<br>OUTFLOWS | | | | | | | | | |
| | | | *លំហូរចេញនៃប្រាក់បញ្ញើរាយ (មិនគិតពីទំហំទឹកប្រាក់) និងប្រាក់បញ្ញើរបស់សហគ្រាសធុនតូចនិងមធ្យម (តិចជាង ឬ ស្មើ ១០០.០០០ ដុល្លារអាមេរិក ឬ សមមូល)*<br>*Retail cash outflows (regardless of amount) and qualifying SME deposits (less than or equal to USD 100,000 or equivalent)* | | | | | | | |
| | 2.11 | 0.05 | ប្រាក់បញ្ញើមានស្ថិរភាព<br>Stable deposits | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.12 | 0.15 | ប្រាក់បញ្ញើមិនសូវមានស្ថិរភាព<br>Less stable deposits | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *ប្រភពទុនដុំមិនមានការធានា*<br>*Unsecured wholesale funding* | | | | | | | |
| | 2.21 | 0.25 | ប្រាក់បញ្ញើប្រតិបត្តិការ (ប្រភពទុនមិនមានការធានាដែលបានពីសេវាកម្មទូទាត់ រក្សាទុក និង គ្រប់គ្រងសាច់ប្រាក់)<br>operational deposits (unsecured funding generated by clearing, custody and cash management activities) | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.22 | 0.4 | ប្រាក់បញ្ញើមិនមែនប្រតិបត្តិការ ពីក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុ ដែលមិនត្រូវរាយការណ៍ក្នុង ២.១១ ដល់ ២.១២<br>non operational deposits from non-financial corp.not qualifying for reporting in 2.11 to 2.12 | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.23 | 0.4 | ប្រាក់បញ្ញើមិនមែនប្រតិបត្តិការ ពីស្ថាប័នអធិបតេយ្យ ធនាគារកណ្តាល និងសហគ្រាស/អង្គភាពសាធារណៈ<br>non operational deposits from sovereigns, central banks, and PSEs | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.24 | 1 | ប្រាក់បញ្ញើមិនមែនប្រតិបត្តិការពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ដូចមានចែងក្នុងឧបសម្ព័ន្ធ ២)<br>non operational deposits from banks and financial institutions (as defined in Annex 2) | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.25 | 1 | ប្រាក់បញ្ញើមិនមែនប្រតិបត្តិការពីនីតិបុគ្គលផ្សេងទៀត<br>non operational deposits from all other legal entities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.26 | 1 | ប្រភពទុនដុំមិនមានការធានាផ្សេងទៀត រួមទាំងមូលបត្របំណុល<br>any other unsecured wholesale funding including debt securities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *ប្រភពទុនមានការធានា*<br>*Secured funding* | | | | | | | |
| | 2.31 | 0 | ប្រតិបត្តិការប្រភពទុនធានាដោយទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់<br>secured funding transactions backed by HQLA | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.32 | 0.15 | ប្រតិបត្តិការប្រភពទុនធានាដោយទ្រព្យសកម្មសន្ទនីយផ្សេងទៀត ក្រៅពីមាស<br>secured funding transactions backed by OLA other than Gold | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.33 | 0.25 | ប្រតិបត្តិការប្រភពទុនធានាដោយមាស<br>secured funding transactions backed by Gold for own account | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.34 | 1 | ប្រតិបត្តិការប្រភពទុនដែលមានការធានាផ្សេងទៀត<br>all other secured funding transactions | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *តម្រូវការសន្ទនីយភាពទាក់ទងនឹងប្រតិបត្តិការឧបករណ៍និស្សន្ទ និងប្រតិបត្តិការផ្សេងទៀត*<br>*Increased liquidity needs related to derivatives and other transactions* | | | | | | | |
| | 2.41 | 1 | ឧបករណ៍និស្សន្ទត្រូវសង<br>derivative payables | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.42 | 1 | លំហូរចេញពីបម្រែបម្រួលតម្លៃទីផ្សារ នៃទ្រព្យធានាលើឧបករណ៍និស្សន្ទ<br>outflows from market valuation changes of collateral for derivative transactions | | | | 0.00 | 0.00 | 0.00 | 0.00 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| លំហូរចេញនៃសាច់ប្រាក់<br>CASH OUTFLOWS | 2.43 | 1 | លំហូរចេញនៃសាច់ប្រាក់ពីប្រតិបត្តិការឧបករណ៍និស្សន្ទផ្សេងទៀត<br>other derivative cash outflows | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | កិច្ចសន្យា<br>Committed facilities | | | | | | | |
| | | | *សមតុល្យមិនទាន់ប្រើប្រាស់នៃកិច្ចសន្យាឥណទាននិងសន្ទនីយភាព*<br>*for the undrawn portion of committed credit and liquidity facilities* | | | | | | | |
| | | | *ចំពោះអតិថិជនរាយនិងសហគ្រាសខ្នាតតូចនិងមធ្យម*<br>*to retails and SMEs* | | | | | | | |
| | 2.51 | 0.05 | កិច្ចសន្យាឥណទាន<br>credit facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.52 | 0.05 | កិច្ចសន្យាសន្ទនីយភាព<br>liquidity facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *ចំពោះក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុ ស្ថាប័នអធិបតេយ្យ និង ធនាគារកណ្តាល*<br>*to non financial corporates, sovereigns and central banks* | | | | | | | |
| | 2.53 | 0.1 | កិច្ចសន្យាឥណទាន<br>credit facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.54 | 0.3 | កិច្ចសន្យាសន្ទនីយភាព<br>liquidity facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ដូចមានចែងក្នុងឧបសម្ព័ន្ធ ២)*<br>*to banks and financial institutions (as defined in Annex 2)* | | | | | | | |
| | 2.55 | 0.4 | កិច្ចសន្យាឥណទាន<br>credit facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.56 | 0.4 | កិច្ចសន្យាសន្ទនីយភាព<br>liquidity facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត*<br>*to other financial institutions* | | | | | | | |
| | 2.57 | 0.4 | កិច្ចសន្យាឥណទាន<br>credit facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.58 | 1 | កិច្ចសន្យាសន្ទនីយភាព<br>liquidity facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *នីតិបុគ្គលផ្សេងទៀត*<br>*to other legal entities* | | | | | | | |
| | 2.59 | 1 | កិច្ចសន្យាឥណទាន<br>credit facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.60 | 1 | កិច្ចសន្យាសន្ទនីយភាព<br>liquidity facilities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *កាតព្វកិច្ចផ្តល់មូលនិធិតាមការផ្សេងៗ (មានកិច្ចសន្យានិងគ្មានកិច្ចសន្យា)*<br>*Other contingent funding obligations (whether contractual or not)* | | | | | | | |
| | 2.71 | 0.1 | កិច្ចសន្យាសន្ទនីយភាពនិងឥណទានដែលអាចបដិសេធបានដោយគ្មានលក្ខខណ្ឌ<br>unconditional revocable credit and liquidity facilities' agreements | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.72 | 1 | កាតព្វកិច្ចទាក់ទងនឹងហិរញ្ញប្បទានពាណិជ្ជកម្ម (រាយការណ៍ចំនួនជាមធ្យមនៃលំហូរចេញសុទ្ធនៃសាច់ប្រាក់ប្រចាំខែក្នុងអំឡុងពេល ១២ខែចុងក្រោយ )<br>trade finance related obligations (report average of monthly net outflows in last 12 month period) | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.73 | 0.5 | ការធានានិងលិខិតឥណទាន ក្រៅពីកាតព្វកិច្ចទាក់ទងនឹងហិរញ្ញប្បទានពាណិជ្ជកម្ម (រាយការណ៍ចំនួនជាមធ្យមនៃលំហូរចេញសុទ្ធនៃសាច់ប្រាក់ក្នុងអំឡុងពេល ១២ខែចុងក្រោយ )<br>Guarantees and letters of credit other than trade finance related obligations (report average of monthly net outflows in last 12 month period) | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 2.81 | 1 | *លំហូរចេញនៃសាច់ប្រាក់តាមការសន្យាផ្សេងទៀត*<br>*Other contractual outflows* | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | សរុប ៤ = ផលបូក (២.១១ ដល់ ២.៨១)<br>Total 4 = Σ ( 2.11 ; 2.81) | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| លំហូរចូលនៃសាច់ប្រាក់ CASH INFLOWS | លំហូរចូល INFLOWS | | | | | | | | | |
| | | | *សមតុល្យ Reverse Repo និងកម្ចីមូលបត្រដែលមានឥណប្រតិទាន ៣០ថ្ងៃ* *Outstanding Reverse repos and securities borrowing with remaining maturities within 30 days* | | | | | | | |
| | | | *ទ្រព្យបញ្ចាំដែលបានទទួល និងមិនត្រូវបានប្រើជាទ្រព្យបញ្ចាំឡើងវិញ* *where the collateral received is not re-hypothecated* | | | | | | | |
| | 3.11 | 0 | បានាដោយទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ covered by HQLA | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.12 | 0.25 | បានាដោយទ្រព្យសកម្មសន្ទនីយផ្សេងទៀត covered by OLA | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.13 | 1 | បានាដោយទ្រព្យសកម្មផ្សេងទៀត covered by other assets | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *ទ្រព្យបញ្ចាំដែលបានទទួល និងត្រូវបានប្រើជាទ្រព្យបញ្ចាំឡើងវិញ* *where the collateral received is re-hypothecated* | | | | | | | |
| | 3.14 | 0 | បានាដោយទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ covered by HQLA | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.15 | 0 | បានាដោយទ្រព្យសកម្មសន្ទនីយផ្សេងទៀត covered by OLA | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.16 | 0 | បានាដោយទ្រព្យសកម្មផ្សេងទៀត covered by other assets | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *កិច្ចសន្យាមិនទាន់ប្រើប្រាស់ ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ២* *Undrawn committed facilities from banks and financial institutions as defined in Annex 2* | | | | | | | |
| | 3.21 | 0 | កិច្ចសន្យាពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមិនបានរាយការណ៍ក្នុង ៣.២២ Committed facilities from banks and financial institutions other than those reported in 3.22 | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.22 | 1 | កិច្ចសន្យាផ្តល់មូលនិធិពីធនាគារមេ Committed fund facilities with parent bank | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *លំហូរចូលពីកិច្ចសន្យាផ្សេងៗ ដែលមានការធានា ឬមិនមានការធានា ក្នុងរយៈពេល ៣០ថ្ងៃ* *Other contractual inflows, either secured or unsecured, within 30 days* | | | | | | | |
| | 3.31 | 0.5 | ពីអតិថិជនរាយ from retail customers | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.32 | 0.5 | ពីសហគ្រាសខ្នាតតូចនិងមធ្យម from SMEs | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.33 | 0.5 | ពីក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុ from non financial corporates | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.34 | 1 | ពីធនាគារកណ្តាល from central banks | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.35 | 1 | ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងឧបសម្ព័ន្ធ ២ from banks and financial institutions as defined in Annex 2 | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.36 | 0.5 | ពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ ២ from other financial institutions as defined in Annex 2 | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.37 | 0.5 | ពីនីតិបុគ្គលផ្សេងទៀត from other legal entities | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.38 | 0.5 | ពីស្ថាប័នអធិបតេយ្យ from sovereigns | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.39 | 1 | ប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងឧបសម្ព័ន្ធ ២ deposits with banks and financial institutions as defined in Annex 2 | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | *លំហូរចូលនៃសាច់ប្រាក់ពីឧបករណ៍និស្សន្ទ* *derivative cash inflows* | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 3.50 | 1 | លំហូរចូលសុទ្ធនៃសាច់ប្រាក់ពីឧបករណ៍និស្សន្ទតាមកិច្ចសន្យារយៈពេល ៣០ថ្ងៃ<br>net contractual derivative cash inflows within 30 days | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.60 | 1 | *លំហូរចូលនៃសាច់ប្រាក់ពីកិច្ចសន្យាមូលបត្រផ្សេងទៀតក្នុងរយៈពេល ៣០ថ្ងៃ*<br>*Contractual inflows from other securities maturing within 30 days* | | | | 0.00 | 0.00 | 0.00 | 0.00 |
| | 3.70 | 0 | *លំហូរចូលនៃសាច់ប្រាក់ពីកិច្ចសន្យាផ្សេងទៀតក្នុងរយៈពេល ៣០ថ្ងៃ*<br>*Any other contractual inflows due in the next 30 days* | | | | 0.00 | 0.00 | 0.00 | 0.00 |
| | | | សរុប ៥ = ដល់បូក (៣.១១ ដល់ ៣.៧០)<br>Total 5 = Σ ( 3.11 ; 3.70) | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| លំហូរចេញសុទ្ធនៃសាច់ប្រាក់<br>TOTAL NET CASH OUTFLOWS | | | សរុប ៦ = សរុប ៤ - អប្បបរមានៃ (សរុប ៥ ឬ ៧៥% នៃ សរុប ៤)<br>Total 6 = Total 4 - Min (Total 5 ; 75% Total 4) | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| អនុបាតគ្របដណ្តប់សន្ទនីយភាព<br>LIQUIDITY COVERAGE RATIO | | | អនុបាតគ្របដណ្តប់សន្ទនីយភាព = សរុប ៣ / សរុប ៦<br>LCR= Total 3/Total 6 | | | | #DIV/0! | #DIV/0! | #DIV/0! | #DIV/0! |